លេខ ០៤ ស.រ -៩៣

# សាធារណរដ្ឋប្រជាមានិតកម្ពុជា

**ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល**

ភ្នំពេញ ថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៩៣

## សារាចរណែនាំ

## រដ្ឋមន្ត្រី ក្រសួងយុត្តិធម៌

## ជម្រាបមក

-ឯកឧត្តម ប្រធានតុលាការកំពូល

-ឯកឧត្តម អគ្គរដ្ឋអាជ្ញាអមតុលាការកំពូល

-លោក ប្រធាន សាលាឧទ្ធរណ៍

-លោកអគ្គរដ្ឋអាជ្ញាអមសាលាឧទ្ធរណ៍

-លោក ប្រធាន តុលាការខេត្ត ក្រុង

-លោក រដ្ឋអាជ្ញាអមតុលាការខេត្ត ក្រុង

-លោក ប្រធានតុលាការយោធា

-លោក រដ្ឋអាជ្ញាអមតុលាការយោធា

**កម្មវត្ថុ:** ការអនុវត្តន៍ច្បាប់ ស្ដីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្ដីនៃកម្ពុជា។

ក្រសួងយុត្តិធម៌មានកិត្តិយស សូមរំលឹកឡើងវិញអំពីការអនុវត្តន៍ច្បាប់ស្ដីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្ដី នៃកម្ពុជាអោយបានជ្រាបថា:

១- អំពីទីស្នាក់ការសាលាឧទ្ធរណ៍

តាមមាត្រា ៣ នៃច្បាប់នេះបានកំណត់ថា សាលាឧទ្ធរណ៍ត្រូវតាំងនៅក្រុងភ្នំពេញ តែមិនទាន់បានកំណត់ទីស្នាក់ការនៅកន្លែងណាមួយក្នុងទីក្រុងភ្នំពេញនៅឡើយទេ ដើម្បីកំណត់ទីស្នាក់ការនេះក្រសួងយុត្តិធម៌សូមជូនដំណឹងថា ទីស្នាក់ការសាលាឧទ្ធរណ៍ត្រូវបានតាំងនៅអតីតសាលាឧទ្ធរណ៍ស្ថិតនៅមុខព្រះបរមរាជវាំង។ ដូច្នេះចាប់ពីពេលនេះតទៅ ក្នុងការទំនាក់ទំនងការងារជាមួយសាលាឧទ្ធរណ៍ឬត្រូវបញ្ជូនមកសាលាឧទ្ធរណ៍ជំនុំជម្រះ ត្រូវធ្វើទំនាក់ទំនងនិងបញ្ជូនមកសាលាឧទ្ធរណ៍ ដែលមានទីស្នាក់ការដូចបានជម្រាបជូនខាងលើ ។

២- អំពីការចុះបណ្ដឹងឧទ្ធរណ៍ ឬ បណ្ដឹងសាទុក្ខ

មាត្រា ៨-៩ និង មាត្រា ១២ នៃច្បាប់ខាងលើនេះបានកំណត់ថាបណ្ដឹងឧទ្ធរណ៍ ឬ បណ្ដឹងសាទុក្ខ បើកអោយប្ដឹងបានក្នុងកំណត់២ ខែ គិតពីថ្ងៃកាត់សេចក្ដីនូវសាលក្រមចំពោះមុខគូក្ដី ឬគិតពីថ្ងៃផុតកំណត់ប្ដឹងបានចំនូវសាលក្រមកំបាំង។

បណ្ដឹងឧទ្ធរណ៍ ឬ បណ្ដឹងសាទុក្ខ ជូនកាលក្នុងរឿងតែមួយគូក្ដីតែម្ខាងប្ដឹងក៏មាន ឬគូក្ដីទាំងសងខាង ប្ដឹងក៏មាន ។ ដូច្នេះ ក្រឡាបញ្ជីដែលទទួលបន្ទុកចុះបណ្ដឹងឧទ្ធរណ៍ ឬបណ្ដឹងសាទុក្ខត្រូវចុះបណ្ដឹងនោះអោយទាំងអស់គ្នាដោយមិនប្រកាន់ជាអ្នកឈ្នះ ឬអ្នកចាញ់ឡើយ និងចុះបញ្ជាក់អំពី ខ បណ្ដឹងអោយបានដឹងថា តើ មិនសុខចិត្តអំពីសាលក្រមទាំងមូល ឬតែអំពីចំណុចណាមួយនោះទេ ។ ឧទាហរណ៍ មិនសុខចិត្តអំពីសាល ក្រមទាំងមូល មិនសុខចិត្តអំពីជម្ងឺចិត្ត ឬ មិនសុខចិត្តអំពីសោហ៊ុយ សំណាង........។ល។ ថ្ងៃ ខែ ទទួលចុះបណ្ដឹងឧទ្ធរណ៍ សូមសរសេរជាអក្សរ ។

ក្នុងរឿងរដ្ឋប្បវេណី បើមានបណ្តឹងឧទ្ធរណ៍ ឬ បណ្តឹងសាទុក្ខនៅពេលទទួលបណ្តឹង ក្រឡាបញ្ជីទទួលបន្ទុកត្រូវណែនាំអោយអ្នកប្តឹងបង់ប្រាក់ប្រដាប់ក្តី សម្រាប់សាលាឧទ្ធរណ៍ ឬតុលាការកំពូល តាមចំនួនដែលច្បាប់កំណត់ហើយត្រូវធ្វើកំណត់ហេតុសម្គាល់អំពីការណែនាំនេះដាក់ក្នុងសំណុំរឿងដោយអោយអ្នកប្តឹង និងក្រឡាបញ្ជីចុះហត្ថលេខាលើកំណត់ហេតុនោះផង។ បើគូក្តីព្រមបង់នៅពេលនោះតែម្តងត្រូវណែនាំអោយធ្វើប្រាក់ប្រដាប់ក្តីនេះតាមអាណត្តិប្រៃសណីយ៍ ដាក់ថាចាងហ្វាងសាលាឧទ្ធរណ៍ ឬចាងហ្វាងតុលាការកំពូល ហើយថាជាប្រាក់ប្រដាប់ក្តី ។

ការណែនាំអោយបង់ប្រាក់ប្រដាប់ក្តីនេះមិនមែនមានន័យថា អ្នកប្តឹងគ្មានប្រាក់បង់ប្រដាប់ក្តីមិនអោយប្តឹងឧទ្ធរណ៍នោះទេ គឺក្នុងន័យថាអ្នកប្តឹងមានប្រាក់បង់ ឬគ្មានប្រាក់បង់ ក្រឡាបញ្ជីត្រូវតែចុះបណ្តឹងឧទ្ធរណ៍ ឬ សាទុក្ខអោយអ្នកប្តឹងជាដ៏រាបតាមសំណូមពររបស់គេ នូវថ្ងៃ ខែ ដែលគេសុំប្តឹងនោះហើយត្រូវតែបញ្ជូនសំណុំរឿងមកសាលាឧទ្ធរណ៍ ឬតុលាការកំពូលតាមការកំណត់ ។

ការណែនាំអោយបង់ប្រាក់ប្រដាប់ក្តីនេះ គ្រាន់តែជាកិច្ចការមួយសំរួលដល់ការងារអោយបានឆាប់ជៀសវាងការយឺតយូរតែប៉ុណ្ណោះ ។

៣- អំពីការបញ្ជូនរឿងមកសាលាឧទ្ធរណ៍ ឬ មកតុលាការកំពូល

ក្រឡាបញ្ជីទទួលបន្ទុកចម្លងសាលក្រមសម្រេច ចម្លងកំណត់ហេតុចេញពីសៀវភៅកំណត់ហេតុជំនុំជម្រះនិងចម្លងសេចក្តីនៃបណ្តឹងតវ៉ាដាក់ក្នុងសំណុំរឿង និងធ្វើបញ្ជីរាយនាមលិខិតដែលមាននៅក្នុងសំណុំរឿង រួចហើយបញ្ជូនសំណុំរឿងនោះ តាមលិខិតអនុសិទ្ធិមកសាលាឧទ្ធរណ៍ ឬ តុលាការកំពូល ។

បើតុលាការដែលមានទីស្នាក់ការនៅជិតក្បែរគ្នាអាច និង បញ្ជូនតាមដីកាបញ្ជូនធម្មតាក៏បានដែរ ។

ការបញ្ជូនសំណុំរឿងពីតុលាការខេត្ត ក្រុង មកសាលាឧទ្ធរណ៍ក្តី ឬពីសាលាឧទ្ធរណ៍មកតុលាការកំពូលក្តី តាមធម្មតាត្រូវតែបញ្ជូនយ៉ាងប្រញាប់ប្រញាល់អោយបានឆាប់បំផុតយ៉ាងយូរក្នុងរយៈ ១ខែ ចាប់ពីថ្ងៃផុតកំណត់ឧទ្ធរណ៍ ឬ ប្តឹងសាទុក្ខ ។

សូមតុលាការខេត្ត ក្រុង តុលាការយោធា សាលាឧទ្ធរណ៍ និងតុលាការកំពូលអនុវត្តតាមការណែនាំនោះអោយបានហ្មត់ចត់ ហើយបើមានចំណុចណាយល់មិនច្បាស់ សូមសួរមកក្រសួងយុត្តិធម៌ ក្រសួងយុត្តិធម៌នឹងឆ្លើយបំភ្លឺតាមសំណូមពរនោះ ។

រដ្ឋមន្ត្រី
ចែម ស្ងួន

<u>ចម្លងជូន:</u>
-ទីស្តីការគណៈរដ្ឋមន្ត្រី
-សភាធម្មនុញ្ញ
-អភិបាលខេត្ត ក្រុង
(ដើម្បីជ្រាបជាព័មាន)